ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៣០៩៦......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតនៅក្នុងភូមិសាស្ត្រត្រូវជាប់ពន្ធលើអចលនទ្រព្យនៃរាជធានី-ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា នៅក្នុងអំឡុងពេលជិតបញ្ចប់ការប្រកាសបង់ពន្ធលើអចលនទ្រព្យ នាថ្ងៃទី៣០ ខែកញ្ញានេះ មានម្ចាស់អចលនទ្រព្យជាច្រើនកំពុងមមាញឹកមកប្រកាសបង់ពន្ធ និងមានម្ចាស់អចលនទ្រព្យមួយចំនួនទៀត ក៏មិនទាន់បានមកប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤ នៅឡើយ។

ដូច្នេះអគ្គនាយកដ្ឋានពន្ធដារបានស្នើសុំ និងបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យពន្យារពេលការផុតកំណត់ការប្រកាសបង់ពន្ធមួយខែទៀតរហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ដើម្បីទុកលទ្ធភាពឱ្យម្ចាស់អចលនទ្រព្យដែលមិនទាន់បានបង់ពន្ធ មានពេលវេលាគ្រប់គ្រាន់មកប្រកាសបង់ពន្ធ។

ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួល និងឆាប់រហ័សដល់ម្ចាស់អចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារបាននិងបន្តឱ្យម្ចាស់អចលនទ្រព្យមកប្រកាសបង់ពន្ធនេះនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមធនាគារ អេស៊ីលីដា ភីអិលស៊ី ឬធនាគារ កាណាឌីយ៉ា ក.អ ណាមួយស្ថិតក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះតាំងនៅ។

ក្នុងករណីម្ចាស់អចលនទ្រព្យទាំងឡាយដែលមិនទាន់បានមកប្រកាសបង់ពន្ធលើអចលនទ្រព្យ ឬមកប្រកាសបង់ពន្ធក្រោយការពន្យារពេលខាងលើ នឹងត្រូវរងទោសទណ្ឌក្នុងការបង់ប្រាក់ពន្ធផង និងបង់ប្រាក់ផាកពិន័យផង ស្របតាមច្បាប់ស្តីពីសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ មានក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអំឡុងពេលពន្យារនេះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា តាមការកំណត់នេះជាក់ជាពុំខាន ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh